# របៀបបំពេញសំណុំពាក្យសុំផលកម្រៃចំណីអាហារ

សូមបំពេញសំណុំពាក្យសុំផលកម្រៃចំណីអាហារ ដោយប្រើអនុទ្ទេសខាងក្រោមនេះ ។
សូមចុះហត្ថលេខាលើសំណុំពាក្យនេះ រួចហើយផ្ញើរទៅកាន់

______________________________________________________________________ ។

ប្រសិនបើលោកអ្នកត្រូវការជួយក្នុងការបំពេញពាក្យនេះ សូមទូរសព្ទ័ទៅលេខ
#______________________________

==================================================

## ១. ពត៌មានរបស់កូន: សូមសរសេរឈ្មោះរបស់កូនលោកអ្នក ឱយបានច្បាស់លាស់ ។

(ក) ប្រសិនលោកអ្នកដាក់ពាក្យសុំចំណីអាហារសាលា សូមបំពេញថាកូនលោកអ្នករៀនថ្នាក់ទីប៉ុន្មាន និងថាតើ សាលាឈ្មោះអ្វីផង ។

(ខ) ប្រសិនលោកអ្នកដាក់ពាក្យសុំចំណីអាហារ សម្រាប់កន្លែងថែទាំកូនក្មេង សូមដាក់ឈ្មោះកន្លែងមើលកូន ឬ ឈ្មោះអ្នកថែទាំកូនលោកអ្នក តាមផ្ទះ ព្រមទាំងឈ្មោះអ្នកធានាផង ប្រសិនបើដឹងនោះ ។

(គ) ប្រសិនបើលោកអ្នក ដាក់ពាក្យសុំចំណីអាហារ នៅក្រោមកម្មវិធី សេវាម្ហូបអាហាររដូវក្តៅនោះ(SFSP) សូមគូសសញ្ញាជើងក្អែកសម្គាល់ផង ។

==================================================

## ២. កូនចិញ្ចឹម: សូមបំពេញផ្នែកនេះ រួចហើយចុះហត្ថលេខាលើពាក្យនេះនៅត្រង់លេខ #៥ ។

(ក) សូមសរសេរប្រាក់ចំណូលប្រចាំខែរបស់កូនចិញ្ចឹម សម្រាប់ការចាយវាយផ្ទាល់ខ្លួនរបស់កូននោះ ។ សូមសរសេរ "0" ប្រសិនបើកូននោះ គ្មានប្រាក់ចំណូលសម្រាប់ចាយវាយផ្ទាល់ខ្លួនទេនោះ ។

(ខ) សូមបំពេញពាក្យដាច់ដោយឡែកពីគ្នា សម្រាប់កូនចិញ្ចឹមនិមួយៗ ។

==================================================

## ៣. ផលកម្រៃដ៏ទៃទៀត: សូមបំពេញផ្នែកនេះហើយចុះហត្ថលេខាលើពាក្យនេះនៅត្រង់ លេខ #៥។

(ក) ប្រសិនលោកអ្នកដាក់ពាក្យសុំចំណីអាហារសាលា សូមបំពេញលេខបច្ចុប្បន្ន របស់ FOOD STAMP លេខប្រាក់ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារខ្វះខាត(TANF) លេខជំនួយសម្រាប់អ្នករស់នៅកន្លែងជនជាតិ INDIAN (FDPIR)សម្រាប់កូនលោកអ្នក ។

(ខ) ប្រសិនជាលោកអ្នកជាអ្នកផ្តល់ការថែទាំកូនតាមផ្ទះ ដាក់ពាក្យសុំប្រាក់កម្រៃកំរិតទី១ សម្រាប់ការថែទាំក្មេងនោះ សូមបំពេញលេខបច្ចុប្បន្ន របស់ FOOD STAMP លេខប្រាក់ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារខ្វះខាត (TANF) លេខជំនួយសម្រាប់អ្នករស់នៅកន្លែងជនជាតិ INDIAN(FDPIR)សម្រាប់លោកអ្នក និងកូនលោកអ្នក ។

(គ) ប្រសិនបើកូនលោកអ្នកចុះឈ្មោះ នៅក្នុងផ្ទះមើលកូនកំរិតទី២(TIER II) សូមរាយឈ្មោះកម្មវិធីគ្រប់លក្ខណៈ ទាំងប៉ុន្មាន និងលេខករណីទាំងនោះផង ប្រសិនជាមាន ។ (សូមមើលបញ្ជីរាយនាមកម្មវិធីដទៃទៀត ដែលផ្ជាប់មកជាមួយនោះ ។)

(ឃ) សូមចុះហត្ថលេខាលើពាក្យនេះ នៅត្រង់លេខ #៥។ មនុស្សពេញវ័យម្នាក់នៅក្នុងគ្រួសារ ចាំបាច់ត្រូវចុះហត្ថលេខា។ លោកអ្នកមិនចាំបាច់បំពេញលេខ SOCIAL SECURITY ទេ ។

==========================================================

## ៤. គ្រួសារដទៃទៀតទាំងអស់: សូមបំពេញផ្នែកនេះ ហើយចុះហត្ថលេខាលើពាក្យនេះ នៅត្រង់លេខ #៥។

(ក) សូមសរសេរឈ្មោះមនុស្សទាំងអស់នៅក្នុងគ្រួសារលោកអ្នក ទោះជាពួកគេគ្មានប្រាក់ចំណូលក៏ដោយ ។ រាប់បញ្ចូលខ្លួនលោកអ្នកផ្ទាល់ ប្តីឬប្រពន្ធលោកអ្នក កូនដែលលោកអ្នកដាក់ពាក្យឱយ ព្រមទាំងសមាជិកឯទៀត ទាំងអស់នៅក្នុងគ្រួសារផង ។

(ខ) សូមសរសេរចំនួនទៃប្រាក់ចំណូល របស់មនុស្សម្នាក់ៗ ដែលទទួលបានកាលពីខែមុន មុនដកពន្ធអាករ ឬ មុនការដកហូតយកអ្វីៗទាំងអស់ចេញ <u>ហើយ</u> ប្រាប់អំពីថាតើប្រាក់ចំណូលទាំងនោះ បានមកពីណា ឧទាហរណ៍ដូចជា ប្រាក់ខែ ប្រាក់ WELFARE ប្រាក់ចូលនិវត្តិ ព្រមទាំងប្រាក់ចំណូលឯទៀត (សូមមើលឧទាហរណ៍ ប្រភេទប្រាក់ចំណូលទាំងឡាយ ដែលត្រូវរាយការ នៅខាងក្រោមនេះ )។ ចំនួនទៃប្រាក់ចំណូលនិមួយៗ គួរតែបញ្ចូល

ស្របទៅតាមខ្នង់ នៅក្នុងពាក្យនេះ ។ ប្រសិនបើចំនួនណាមួយ <u>ពីខែមុន</u> មានតិច ឬ ច្រើនជាងធម្មតានោះ សូមសរសេរចំនួនប្រាក់ចំណូល តាមធម្មតារបស់បុគ្គលនោះ ។

(គ) ប្រសិនបើមានអ្នកណាម្នាក់ ធ្វើការឱយខ្លួនឯងនោះ សូមសរសេរប្រាក់ចំណូលរបស់អ្នកនោះ ពីការងាររបស់ខ្លួនឯង ឧទាហរណ៍ ប្រាក់ចំណូលបានមកពីការថែទាំកូនក្មេងនៅក្នុងផ្ទះ ឬ ការធ្វើស្រែចំការ ជាដើមនោះ ។ សូមទូរសព្ទ័ទៅលេខ នៅខាងលើបំផុតនៃទំព័រនេះ ប្រសិនបើលោកអ្នកត្រូវការឱយគេជួយនោះ ។

(ឃ) ប្រសិនបើលោកអ្នក ជាអ្នកផ្តល់ការថែទាំកូនក្មេងតាមផ្ទះ ដាក់ពាក្យសុំផលកម្រៃកំរិតទី១នោះ(Tier I) សូមផ្ជាប់នូវឯកសារ ប្រាក់ចំណូល បញ្ជាក់ទ្រទ្រង់ថានះរបស់លោកអ្នកផង ។

(ង) សូមចុះហត្ថលេខាលើសំណុំពាក្យ ហើយ បំពេញលេខ SOCIAL SECURITY របស់លោកអ្នក នៅក្នុងលេខ #៥ ផង។ ប្រសិនបើលោកអ្នកគ្មានលេខនេះទេ សូមសរសេរថា "NONE" ។

---

## ៥. ហត្ថលេខា និង លេខ SOCIAL SECURITY:

(ក) ពាក្យនេះចាំបាច់ត្រូវតែមានហត្ថលេខា របស់សមាជិកគ្រួសារម្នាក់ដែលជាមនុស្សធំពេញវ័យ ។

(ខ) សមាជិកគ្រួសារម្នាក់ដែលជាមនុស្សធំពេញវ័យ ដែលចុះហត្ថលេខាលើពាក្យនេះ ចាំបាច់ត្រូវតែបំពេញលេខ SOCIAL SECURITY របស់ខ្លួន ។ ប្រសិនបើសាម៉ីខ្លួន គ្មានលេខនេះទេនោះ សូមសរសេរថា "NONE" ប្រែថាគ្មាន ។ លេខ SOCIAL SECURITY ជាការមិនចាំបាច់ទេ ប្រសិនលោកអ្នកមានចុះលេខប្រាក់ FOOD STAMP លេខប្រាក់ជំនួយបណ្តោះអាសន្នស្រាប់គ្រួសារខ្វះខាត(TANF) ឬ លេខករណីយ ជំនួយដល់គ្រួសាររស់នៅកន្លែងជនជាតិ INDIAN (FDPIR) នោះ ឬ ប្រសិនលោកអ្នកដាក់ពាក្យសុំឱយកូនចិញ្ចឹមម្នាក់នោះ ។

(គ) ប្រសិនបើលោកអ្នកដាក់ពាក្យសុំផលកម្រៃ ក្នុងថានះជាអ្នកផ្តល់ការថែទាំកូនក្មេងតាមផ្ទះនោះ(Tier I) សូមបញ្ជាក់ឱយដឹងអំពីរឿងនេះ នៅក្នុងផ្នែកនៃពាក្យនេះផង ។

---

៦. ការសម្គាល់ពូជសាសន៍: ច្បាប់មិនតម្រូវឱ្យលោកអ្នកឆ្លើយនិងសំណួរនេះ ដើម្បីទទួលផលកម្រៃម្ហូបអាហារឡើយ ក៏ប៉ុន្តែការផ្តល់ពត៌មាននេះ និងជួយធានារ៉ាប់រងថា ជនរាល់រូបបានទទួលការពិចារណាស្មើៗគ្នាទាំងអស់។

================================================================

# ប្រាក់ចំណូលដែលត្រូវរាយការ

<u>ប្រាក់ចំណូលបានមកពីការងារ</u>

ប្រាក់ខែ ប្រាក់ម៉ោង និងប្រាក់ភ្ញៀវឱ្យក្រៅ(Tips)

ប្រាក់បានមកពីការធ្វើកូដកម្ម

ប្រាក់បានមកពីការបាត់បង់ការងារធ្វើ

ប្រាក់បានសំណងសម្រាប់អ្នកធ្វើការ

ប្រាក់ចំណូល ក្រោយការដកហូតពន្ធដា បានមកពីមុខរបររកស៊ីផ្ទាល់ខ្លួន មុខរបរថែទាំកូនក្មេង ឬ ការធ្វើកសិកម្ម

<u>ប្រាក់សុខមាលភាព/ប្រាក់សម្រាប់ចិញ្ចឹមកូន</u>

ប្រាក់ជំនួយសាធារណៈ

ប្រាក់សុខមាលភាព(welfare)

ប្រាក់សម្រាប់យកទៅចិញ្ចឹមកូន បានមកពីការលែងលះគ្នា

<u>ប្រាក់ចូលនិវត្តិ / និងប្រាក់សន្តិសុខសង្គម(Social Security)</u>

ប្រាក់ចូលនិវត្តិ

ប្រាក់ចំណូលបន្ថែមសម្រាប់អ្នកចូលនិវត្តិ

ប្រាក់សម្រាប់ទាហានជើងចាស់

ប្រាក់សន្តិសុខសង្គម

ប្រាក់ចំណូលប្រចាំខែឯទៀត / ប្រាក់បានមកពីមុខរបរផ្ទាល់ខ្លួន

ប្រាក់បំណាច់សម្រាប់ជនពិការ

ប្រាក់សុទ្ធដកចេញពីការសន្សំទុកពីមុនមក

ប្រាក់ការ / ប្រាក់ចំណេញចែកគ្នា

ប្រាក់ចំណូលបានមកពីទ្រព្យសម្បត្តិ / និងពីការធ្វើវិនិយោគ

វិភាគទានជាប្រក្រតី ពីអ្នកដែលមិនមែនរស់នៅក្នុងគ្រួសារ

ប្រាក់កម្រៃអ្នកនិពន្ធ ប្រាក់ចំណូលប្រចាំឆ្នាំ បានមកពីវិនិយោគទុន ប្រាក់បានមកពីការជួលផ្ទះ

ប្រាក់សម្រាប់ឱយទាហាន យកទៅសងថ្លៃផ្ទះ នៅក្រោយបន្ទាយ

ប្រាក់ចំណូលដទៃទៀត ។

Cambodian